# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ..១៣....អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើត គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលសរសេរជាអក្សរកាត់ថា **គ.ស.អ.ស.ក.** និងសរសេរជាភាសាអង់គ្លេស Coordinating Committee for the Development of Informal Economy ដែលសរសេរជាអក្សរកាត់ថា CCDIE មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ហែម វណ្ណឌី** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **មាន សុភា** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៤- ឯកឧត្តម **អេង ភក្តថាយ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | |
|---|---|---|
| ៥- ឯកឧត្តម **យឹម ឈាត** | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៦- ឯកឧត្តម **ហាប់ ទូច** | រដ្ឋលេខាធិការប្រចាំការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧- ឯកឧត្តម **ឆាន់ ចាន់ធុល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម **ស៊ុន ដារ៉ាវន្ត** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- ឯកឧត្តម **ស៊ុយ ឌីម៉ង់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១- ឯកឧត្តម **សំរិត មករា** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២- ឯកឧត្តម **ស៊ូនី វឌ្ឍឫទ្ធិសិដ្ឋ** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣- ឯកឧត្តម **រស់ សាលីន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤- ឯកឧត្តម **ង៉ូច បូរីណា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥- ឯកឧត្តម **សុ វិសុទ្ធី** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៦- លោកជំទាវ **ឥម នីថារ៉ា** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកា |
| ១៧- លោកជំទាវ **ហ៊ុន ដានី** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកា |
| ១៨- លោកជំទាវបណ្ឌិត **ត្រី ណារ៉ាល់លីស** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១៩- ឯកឧត្តម **គួច សុមាន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២០- ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ២១- ឯកឧត្តមបណ្ឌិត **ឈៀង វណ្ណមុនិណ្ណ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកប្រតិបត្តិសហគ្រិនខ្មែរ | សមាជិក |
| ២២- ឯកឧត្តម **គិត សេង** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៣- លោកជំទាវ **ពៅ វរលក្សណ៍** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិកា |
| ២៤- ឯកឧត្តម **យិន ខូនភូលេនីន** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២៥- ឯកឧត្តម **គិម ហុង** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ២៦- ឯកឧត្តម **ម៉ុន បុណ្យសារ៉ាត់** | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |

| | | |
|---|---|---|
| ២៧- ឯកឧត្តម **ពៅ ចណ្ណា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២៨- ឯកឧត្តម **ម៉េង ហុង** | អគ្គនាយកស្ដីទីនៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| ២៩- ឯកឧត្តម **យុន ហេង** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣០- ឯកឧត្តម **ប្រាក់ សោភ័ណ** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ៣១- ឯកឧត្តមបណ្ឌិត **សោម ពិសិដ្ឋ** | អភិបាលនៃគណៈអភិបាលខេត្តកែប | សមាជិក |
| ៣២- លោក **កែ សួនសុភាព** | អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ៣៣- លោក **ផេង សិទ្ធី** | អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ៣៤- លោក **ឡោ ចាន់លី** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម | សមាជិក |
| ៣៥- លោក **យ៉េង តិរម្យ** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៣៦- លោក **ស្រ៊ុន ស្រ៊ន់** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ៣៧- លោក **ខួន រាសី** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |
| ៣៨- លោក **ពេញ ធារម្យ** | អភិបាលរងនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ៣៩- លោក **ម៉ុន ផេង** | អភិបាលរងនៃគណៈអភិបាលខេត្តកណ្ដាល | សមាជិក |
| ៤០- លោក **ស្រេង ហុង** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | សមាជិក |
| ៤១- លោក **សួស សេរីសួស្តី** | អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| ៤២- លោក **សាន់ ដារិទ្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៤៣- លោក **ខួន ដារ័ត្ន** | អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៤៤- លោក **មុត តិសិទ្ធរ** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| ៤៥- លោក **ពេជ្រ សុគ្គារ័ត្ន** | អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ៤៦- លោក **ខួន ប៉ោចសេង** | អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ៤៧- លោក **ខិន ណែល** | អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ៤៨- លោក **ហែម ដារិទ្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ៤៩- លោក **ញ៉ែម សារី** | អភិបាលរងនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ៥០- លោក **សុខា រ៉ម** | អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង | សមាជិក |
| ៥១- លោក **យស់ សុខឡូនា** | អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ៥២- លោក **សច់ រីហោ** | អភិបាលរងនៃគណៈអភិបាលខេត្តឧត្ដរមានជ័យ | សមាជិក |
| ៥៣- លោក **ខួន លីណា** | អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ៥៤- លោក **ហុក ពេជ្រហោះ** | អភិបាលរងនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ៥៥- លោកស្រីសាស្ត្រាចារ្យបណ្ឌិត **មូ ច័ន្ទគុលិកា** | ប្រធាននាយកដ្ឋានគោលនយោបាយនៃក្រសួង អប់រំ យុវជន និងកីឡា | សមាជិកា |

| | | |
|---|---|---|
| ៥៦- លោកវេជ្ជបណ្ឌិត **លី វិជ្ជារ៉ាវុធ** | ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល | សមាជិក |
| ៥៧- លោក **ជ័យ រិទ្ធី** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យមនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥៨- លោក **តាំ ច័ន្ទកុសល** | ប្រធានលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥៩- ឯកឧត្តមបណ្ឌិត **កៅ ថាច** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | សមាជិក |
| ៦០- ឯកឧត្តមបណ្ឌិត **តាំង ខួនលី** | នាយកមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" | សមាជិក |
| ៦១- លោកបណ្ឌិត **លឹម អូន** | អគ្គនាយកធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា | សមាជិក |
| ៦២- ឧកញ៉ា **ខួន ម៉េងតិច** | អគ្គនាយកនៃសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ៦៣- ឧកញ៉ា **កែវ មុំ** | ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា | សមាជិកា |
| ៦៤- លោកបណ្ឌិត **ហោ សេរីវឌ្ឍន៍** | ប្រធានសម្ព័ន្ធសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសមាគមវិនិយោគ នវានុវត្តន៍ និងអភិវឌ្ឍន៍ | សមាជិក |
| ៦៥- ឧកញ៉ា **មិុច បូឡែន** | ប្រធានសមាគមសហគ្រិនវ័យក្មេងកម្ពុជា | សមាជិក |
| ៦៦- ឯកឧត្តម **មៀច សុខទ្រី** | ប្រធានសមាគមអ្នកផលិតចំណីអាហារកម្ពុជា | សមាជិក |
| ៦៧- ឧកញ៉ា **សុខ ដារ៉ា** | អនុប្រធានក្រុមប្រឹក្សាភិបាលសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា | សមាជិក |
| ៦៨- លោក **កាំង ម៉ូនីកា** | អគ្គលេខាធិការរងសមាគមវាយនភណ្ឌសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា | សមាជិក |
| ៦៩- ឯកឧត្តមបណ្ឌិត **ឡី សុភាព** | ប្រធានសមាគមសហព័ន្ធយុវជនសេដ្ឋកិច្ចកម្ពុជា | សមាជិក |
| ៧០- លោក **លួស សីហា** | ប្រធានសមាគមទ្រទ្រង់ផ្នែកសេវាកម្មហិរញ្ញវត្ថុនិងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា | សមាជិក |
| ៧១- លោក **ឈឿន វ៉ាន់យ៉ា** | ប្រធានក្រុមប្រឹក្សាភិបាលសមាគមរួមគ្នាអភិវឌ្ឍន៍ដើម្បីសន្តិភាព | សមាជិក |
| ៧២- លោកបណ្ឌិត **ហោ គន្ធា** | ប្រធានសមាគមអភិវឌ្ឍន៍វិជ្ជាជីវៈអ្នកសារព័ត៌មានកម្ពុជា | សមាជិក។ |

**មាត្រា២ ._**

**គ.ស.អ.ស.ភ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- រិះរកដំណោះស្រាយចំពោះទិដ្ឋភាពច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តផ្សេងៗ ដែលអាចកើតមានជាលក្ខណៈអន្តរស្ថាប័ន និងអន្តរវិស័យពាក់ព័ន្ធនឹងការអនុវត្ត ដើម្បីស្នើសុំការពិនិត្យសម្រេចពីប្រមុខរាជរដ្ឋាភិបាលតាមយថានុរូប
- ពិនិត្យ និងអនុម័តសូចនាករសមិទ្ធកម្មគន្លឹះ និងកម្រងសំណើផែនការសកម្មភាពលម្អិតរបស់ក្រសួង ស្ថាប័នដើម្បីស្នើសុំហិរញ្ញប្បទានថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជនលើការងារលើកស្ទួយសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- លើកយោបល់កែសម្រួលយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងវិធានគន្លឹះតាមការចាំបាច់ ដើម្បីស្នើសុំការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៣ ._**

អនុប្រធាន និងសមាជិក **គ.ស.អ.ស.ភ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ស.អ.ស.ភ.**។

ប្រធាន **គ.ស.អ.ស.ភ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំប្រជុំជំនួសបាន ក្នុងករណីចាំបាច់។

**មាត្រា៤ ._**

ប្រធាន **គ.ស.អ.ស.ភ.** មានសិទ្ធិអញ្ជើញឥស្សរជនដែលជាតំណាងក្រសួង ស្ថាប័ន អង្គភាពផ្សេងទៀត និងតំណាងពីវិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីចូលរួមប្រជុំ និងផ្តល់យោបល់តាមការចាំបាច់។

**មាត្រា៥ ._**

**គ.ស.អ.ស.ភ.** អាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារចំពោះកិច្ចតាមការចាំបាច់។

**មាត្រា៦ ._**

**គ.ស.អ.ស.ភ.** មានលេខាធិការដ្ឋានមួយដែលស្ថិតក្រោមចនាសម្ព័ន្ធនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាសេនាធិការក្នុងការជួយសម្របសម្រួលដំណើរការការងាររបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ស.អ.ស.ភ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.អ.ស.ភ.** និងជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា៧ .-**

គ.ស.អ.ស.ក. និងលេខាធិការដ្ឋាន គ.ស.អ.ស.ក. មានសិទ្ធិប្រើត្រារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ